រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

(គ.ជ.អ.ប)

# ឯកសារបច្ចេកទេស
# ស្តីពី
# ការលើកកម្ពស់សមធម៌សង្គម
# និងបរិយាប័ន្ននៅថ្នាក់ក្រោមជាតិ

លេខាធិការដ្ឋាន គ.ជ.អ.ប

ខែកញ្ញា ឆ្នាំ ២០១៦

# ផ្នែកទី១
# ទិដ្ឋភាពទូទៅនៃការលើក
# កម្ពស់សមធម៌សង្គម
# និងបរិយាប័ន្ន

# ផ្នែកទី១
# ទិដ្ឋភាពទូទៅ
# នៃការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន

ផ្នែកនេះ រៀបរាប់ពីមូលដ្ឋានគ្រឹះនៃការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន ដែលរួមមាន និយមន័យ ក្រុមគោលដៅ គោលបំណងនៃការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន។ លើសពីនេះទៀត ផ្នែកនេះក៏បានផ្តល់ឧទាហរណ៍មួយចំនួន ដើម្បីផ្តល់ជាធាតុចូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិចារណាការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្នក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចនិងការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន។

## ១.១. និយមន័យ

### ១.១.១. សមធម៌សង្គម

នៅក្នុងបរិបទនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពាក្យថា "សមធម៌សង្គម" មានន័យថា ៖

- ជាការលើកកម្ពស់សិទ្ធិរបស់ជនគ្រប់រូបនៅក្នុងសង្គមក្នុងការទទួលបាន និងការប្រើប្រាស់ប្រកបដោយសមធម៌នូវផលប្រយោជន៍ពីការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- ជាការលើកកម្ពស់សិទ្ធិរបស់ជនគ្រប់រូបក្នុងការចូលរួមសកម្មភាព នានាយ៉ាងពេញលេញលើផ្នែក សង្គម នយោបាយ សេដ្ឋកិច្ច វប្បធម៌នៅក្នុងសង្គម ឬសហគមន៍របស់ពួកគេ ក៏ដូចជាសិទ្ធិក្នុងការកំណត់ដោយខ្លួនឯង ដើម្បីសម្រេចបាននូវសេចក្តីត្រូវការជាមូលដ្ឋាននានារបស់ខ្លួន។

ជាមួយគ្នានេះក្នុងការងាររដ្ឋបាលសាធារណៈ “សមធម៌សង្គម” សំដៅលើការគ្រប់គ្រងស្ថាប័ននានាដែលបម្រើផលប្រយោជន៍សាធារណៈ ការផ្តល់សេវាសាធារណៈ ការរៀបចំ និងការអនុវត្តគោលនយោបាយ ព្រមទាំងលិខិតបទដ្ឋាននានា ប្រកបដោយសមធម៌ចំពោះជនគ្រប់រូបនៅក្នុងសង្គម។

ជារួមការលើកកម្ពស់សមធម៌សង្គម គឺជាការចាត់វិធានការជាក់លាក់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋរួមបញ្ចូលទាំងជន ឬក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះ តាមរយៈការដោះស្រាយនូវភាពខុសគ្នានៃតម្រូវការ ការរើសអើង និងការបាត់បង់ឱកាសក្នុងចំណោមក្រុមប្រជាពលរដ្ឋផ្សេងៗគ្នា។ ឧទាហរណ៍៖ បង្កើនការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច ការលុបបំបាត់ភាពរាំងស្ទះក្នុងការចូលរួមរបស់ជនពិការ ការផ្តល់អាហារូបករណ៍ដល់សិស្សស្រីប្រុស ជនជាតិដើមភាគតិចជាដើម។

### ១.១.២. បរិយាប័ន្ន

បរិយាប័ន្ន គឺជាដំណើរការដែលធានាថាប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមបានពេញលេញនៅក្នុងដំណើរការរៀបចំគោលនយោបាយ ផែនការ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ដោយឡែកនៅក្នុងសង្គមមានទម្រង់នៃទំនាក់ទំនងផ្សេងៗគ្នាជាច្រើន ដែលក្នុងនោះមានទម្រង់ទំនាក់ទំនងពីរដែលរាំងស្ទះដល់ការចូលរួមរបស់ប្រជាពលរដ្ឋដូចជា៖

ការផាត់ចេញពីសង្គម



#### ក. ការផាត់ចេញពីសង្គម

មានបុគ្គល ឬក្រុមមួយចំនួនត្រូវបានផាត់ចេញពីសង្គមដោយសារតែប្រវត្តិ

សាវតា ស្ថានភាពរស់នៅ ទិន្នាការនយោបាយ សាសនា ឬបញ្ហាសុខភាពរបស់ពួកគេជាដើម។ ឧទាហរណ៍៖ ជនពិការ ឬអ្នកដែលផ្ទុកមេរោគអេដស៍មួយចំនួនត្រូវបានគេផាត់ចេញពីការចូលរួមសកម្មភាពនានានៅក្នុងសង្គម។

### ខ. ការដាច់ដោយឡែកពីសង្គម

មានក្រុមមនុស្សមួយចំនួនអាចរស់នៅដាច់ដោយឡែកពីសង្គម ដោយសារតែកត្តាប្រពៃណី និងប្រភពកំណើតរបស់ពួកគេជាដើម។ ករណីនេះភាគច្រើនអាចកើតឡើងចំពោះក្រុមជនជាតិភាគតិច និងជនជាតិដើមភាគតិច ដែលមិនអាចនិយាយភាសាខ្មែរបានពួកគេត្រូវថែរក្សានូវប្រពៃណីរបស់ខ្លួន។ ក្រៅពីនេះនៅមានក្រុមជនជាតិភាគតិច និងជនជាតិដើមភាគតិចមួយចំនួនទៀត ដែលអាចថែរក្សាប្រពៃណីរបស់ពួកគេបាន ប៉ុន្តែពួកគេនៅតែមិនអាចចូលរួមក្នុងកិច្ចការសង្គមបាន ដោយសារពួកគេពុំមានតំណាងរបស់ខ្លួននៅក្នុងថ្នាក់ធ្វើសេចក្ដីសម្រេច ឬលទ្ធភាពទទួលបានការអប់រំ និងការងារធ្វើនៅមានកម្រិត។



ផ្អែកតាមចំណុច "ក" និងចំណុច "ខ" ខាងលើឃើញថា នៅក្នុងសង្គម ឬសហគមន៍នីមួយៗ មានបុគ្គល ឬក្រុមមនុស្សមួយចំនួនត្រូវបានគេផាត់ចេញពីសង្គម រស់នៅដាច់ដោយឡែក និងមិនត្រូវបានគេយកចិត្តទុកដាក់ ឬត្រូវគេរើសអើង។ ក្នុងន័យនេះ បរិយាប័ន្ន គឺដើម្បីចៀសវាងនូវរាល់ទម្រង់ទាំងអស់នៃការផាត់ចេញពីសង្គម ឬការរស់នៅដាច់ដោយឡែកពីសង្គមរបស់បុគ្គលម្នាក់ៗ ឬជាក្រុម។

នៅក្នុងបរិបទនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពាក្យថា "បរិយាប័ន្ន" មានន័យថាជាការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងទទួលផលពីសកម្មភាពនានារបស់សង្គមដោយគ្មានការរើសអើង។




ដូច្នេះ ការលើកកម្ពស់បរិយាប័ន្ន នៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺមិនត្រឹមតែធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាប៉ុណ្ណោះទេ ថែមទាំងយកចិត្តទុកដាក់ដល់ការចូលរួមរបស់ប្រជាពលរដ្ឋ រួមទាំងជន ឬក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះ ដើម្បីធានាថាសិទ្ធិជាមូលដ្ឋាន និងតម្រូវការរបស់ពួកគាត់ត្រូវបានទទួលស្គាល់ និងឆ្លើយតប។ ឧទាហរណ៍៖ ការចូលរួមនៅក្នុងដំណើរការរៀបចំផែនការ ការផ្តល់សេវា និងការសម្រេចចិត្តក្នុងការអភិវឌ្ឍមូលដ្ឋានជាដើម។

## ១.២. ក្រុមគោលដៅ

ដើម្បីធានាថាការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ត្រូវបានធ្វើឡើងប្រកបដោយសមធម៌ មិនមានការរើសអើង មានការចូលរួម និងឆ្លើយតបដល់តម្រូវការរបស់ជនគ្រប់រូបនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិ គួរកំណត់ឱ្យបានច្បាស់នូវក្រុមគោលដៅណាខ្លះដែលមិនបានចូលរួម មិនទាន់បានទទួលផលប្រយោជន៍ ឬមានការលំបាកក្នុងការចូលរួម ឬការទទួលបានផលប្រយោជន៍ពីការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។

ជារឿយៗជន ឬក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះភាគច្រើនទទួលរងការរើសអើង និងការផាត់ចេញពីសង្គមខ្ពស់ជាងប្រជាពលរដ្ឋ

ទូទៅ ដែលធ្វើឱ្យពួកគាត់មិនបាន ឬពិបាកក្នុងការទទួលបានសេវាសាធារណៈ និងចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋានដូចជា បាត់បង់ឱកាសក្នុងការទទួលបានការអប់រំ ការទទួលបានការងារ ឬការចូលរួមសកម្មភាពនានានៅក្នុងសង្គមជាដើម។

ការកំណត់ក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះមានភាពខុសៗគ្នាពីតំបន់មួយទៅតំបន់មួយអាស្រ័យលើស្ថានភាពភូមិសាស្ត្រ សង្គម សេដ្ឋកិច្ច និងវប្បធម៌។

ជាទូទៅ ក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះចម្បងៗនៅក្នុងសង្គម ឬសហគមន៍រួមមាន៖

- **ស្ត្រី** ៖ ការយល់ឃើញអំពីតួនាទីរបស់ស្ត្រី និងបុរសតាមប្រពៃណី នៅតែជាបញ្ហារាំងស្ទះក្នុងការទទួលបានការងារ និងចូលរួមក្នុង សកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម និងនៅក្នុងឱកាសផ្សេងៗទៀត។ ជាក់ស្តែង ចំនួនស្ត្រីនៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានចំនួនតិច អត្រាស្ត្រីរងគ្រោះដោយសារអំពើហិង្សា និងការបោះបង់ចោលការសិក្សានៅមានកម្រិតខ្ពស់នៅឡើយដែលបានបង្ហាញពីគម្លាតរវាងបុរសនិងស្ត្រី។
- **ជនពិការ** ៖ ពួកគាត់មានការប្រាស្រ័យទាក់ទងគ្នាខុសពីមនុស្សធម្មតាទាំងកាយសម្បទា ភាពរំញោច និងសតិបញ្ញាស្មារតី ហើយភាពខុសគ្នាទាំងនេះមិនត្រូវបានសង្គមយកចិត្តទុកដាក់។ ដោយសារកត្តាទាំងនេះហើយ ជារឿយៗជនពិការភាគច្រើនបានបាត់បង់ឱកាស និងងាយទទួលរងគ្រោះដោយសារតែពួកគេមួយចំនួនត្រូវបានគេផាត់ចេញពីសង្គម

ដូចជា ទទួលបានការអប់រំតិចតួច បាត់បង់ឱកាសការងារ មិនបានចូលរួមក្នុងសកម្មភាពនានានៅក្នុងសង្គម និងត្រូវបានគេរើសអើងផងដែរ។

- **ជនជាតិដើមភាគតិច ៖** ជាញឹកញាប់ ជនជាតិដើមភាគតិច ត្រូវបានផាត់ចេញពីសង្គមដោយសារភាពខុសគ្នានៃវប្បធម៌ ប្រពៃណី និងជំនឿសាសនារបស់ពួកគាត់ និងទីតាំងភូមិសាស្ត្ររស់នៅដាច់ពីគេ។
- **មនុស្សចាស់ ៖** ជារឿយៗ មនុស្សចាស់ភាគច្រើនរស់នៅដាច់ដោយឡែកពីសង្គម ដែលពិបាកនឹងប្រើប្រាស់សេវាសុខភាព ឬសេវាសង្គមនានា ជាពិសេសមនុស្សចាស់ដែលរស់នៅតាមទីជនបទ។ ជាការពិតណាស់ មនុស្សចាស់មានតម្រូវការនានាខុសពីមនុស្សវ័យកណ្ដាល ឬក្មេង។ ដូច្នេះរដ្ឋបាលថ្នាក់ក្រោមជាតិក៏គួរពិចារណា និងឆ្លើយតបទៅនឹងតម្រូវការរបស់មនុស្សចាស់ទាំងនោះផងដែរ។
- **ជនជាតិភាគតិច ៖** ជាញឹកញាប់ ជនជាតិភាគតិចត្រូវបានផាត់ចេញពីសង្គម ដោយសារភាពខុសគ្នានៃវប្បធម៌ ប្រពៃណី និងជំនឿសាសនារបស់ពួកគេ។
- **ជនចំណាកស្រុក ៖** មនុស្សពេញវ័យជាច្រើនបានធ្វើចំណាកស្រុកពីតំបន់មួយទៅតំបន់ដទៃទៀតទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ហើយពួកគេទាំងនោះប្រឈមនឹងការជួញដូរពលកម្មផ្លូវភេទ និងការរំលោភបំពានផ្សេងៗ។ ក្នុងនោះទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ដល់សុខុមាលភាពរបស់ពួកគេ ជាពិសេសជនចំណាក

ស្រុកនៅក្នុងប្រទេស និងជានាថាពួកគេទទួលបានសិទ្ធិ និងសេវាមូលដ្ឋានចាំបាច់នានា។

- **ជនអន្តោប្រវេសន្ត ៖** នៅក្នុងសង្គម ឬសហគមន៍មួយចំនួន មានការរើសអើងចំពោះជនបរទេស ដោយសារកត្តាជាតិសាសន៍ ពណ៌សម្បុរ សាសនា វប្បធម៌ផ្សេង និងភាសាជាដើម។ ដោយសារកត្តាទាំងនេះហើយបានក្លាយជាបញ្ហារាំងស្ទះក្នុងការធ្វើសមាហរណកម្មជនអន្តោប្រវេសន្តទាំងនោះទៅក្នុងសង្គម ឬសហគមន៍ ដែលគេកំពុងរស់នៅ។
- **កុមារនៃគ្រួសារក្រីក្រ ៖** កុមាររស់នៅក្នុងគ្រួសារក្រីក្រ កុមារអនាថា កុមារកំព្រា ពិបាកក្នុងការទទួលបានឱកាសចូលសិក្សារៀនសូត្រនៅតាមសាលា និងឱកាសចូលរួមក្នុងសកម្មភាពនានានៅក្នុងសហគមន៍ សង្គម ដោយសារតែពួកគេចាប់ផ្តើមធ្វើការទាំងនៅវ័យក្មេង ឬចំណាកស្រុកដើម្បីរកចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ។



- **យុវជន ៖** ប្រទេសកម្ពុជាកំពុងឋិតនៅក្នុងដំណាក់កាលមួយដែលក្រុមយុវជនមានចំនួនច្រើនបំផុត។ ក្រុមនេះមានសក្តានុពល ក្នុងការកំណត់អំពីអនាគត និងជោគវាសនារបស់ប្រទេសជាតិ ទាំងផ្នែកសង្គមកិច្ច សេដ្ឋកិច្ចជាដើម។ ប៉ុន្តែយុវជនមួយចំនួនបានបោះបង់ចោលការសិក្សា រៀបការនៅវ័យក្មេង ធ្វើការចំណាកស្រុក ប្រើប្រាស់គ្រឿងញៀន ឬ

គ្រឿងស្រវឹង និងប្រព្រឹត្តនូវឥរិយាបថគ្រោះថ្នាក់ផ្សេងៗ ដែលជាកត្តាហានិភ័យ ធ្វើឱ្យពួកគេបាត់បង់ឱកាសអភិវឌ្ឍបុគ្គល និងសង្គម។ ក្នុងករណីដែលមិនមានការវិនិយោគឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដើម្បីលើកកម្ពស់ស្ថានភាពយុវជននោះទេ ក្រុមនេះមិនត្រឹមតែមិនអាចចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គមបានទេ តែបែរជាអាចប្រែក្លាយទៅជាជន ឬក្រុមងាយរងគ្រោះ ដែលបង្កបញ្ហាដល់សង្គមទៅវិញ។

ក្រៅពីជន ឬក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះ ដូចបានរៀបរាប់ខាងលើនៅក្នុងសង្គម ឬសហគមន៍នីមួយៗអាចមានជន ឬក្រុមបាត់បង់ឱកាស និងជនងាយរងគ្រោះផ្សេងៗទៀតដូចជា ប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទ អ្នកដែលសេពគ្រឿងញៀន ឬគ្រឿងស្រវឹង អ្នកផ្ទុកមេរោគអេដស៍ អ្នកស្រលាញ់ភេទដូចគ្នា អ្នកកែភេទ ក្មេងទំនើង អ្នកធ្វើការផ្នែកបម្រើសេវាកំសាន្តសប្បាយជាដើម។

## ១.៣. គោលបំណង

ការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន មានគោលបំណងធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់រូប រួមទាំងក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះ តាមរយៈការដោះស្រាយនូវភាពខុសគ្នា និងវិសមភាពក្នុងចំណោមក្រុមប្រជាពលរដ្ឋផ្សេងៗគ្នាដោយ៖

- ផ្តល់នូវសិទ្ធិជាមូលដ្ឋានដល់ក្រុមផ្សេងៗគ្នា ជាពិសេសក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះឱ្យទទួលបាននូវឱកាសសមស្រប (ឱកាសស្មើៗគ្នាសម្រាប់មនុស្សគ្រប់រូប)
- ធានាថាមតិយោបល់ និងការយល់ឃើញនានារបស់ក្រុមទាំងនោះត្រូវបានយកមកពិចារណាសម្រាប់ការធ្វើសេចក្តី

សម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ (ការចូលរួមពេញលេញ)

- ធានាឱ្យពួកគេទទួលបាន និងប្រើប្រាស់ដោយសមធម៌នូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត។

ការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ននឹងធានាឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងមានសុខដុមនីយកម្មនៅក្នុងសង្គម និងសហគមន៍។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន នៅក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ បើមិនដូច្នោះទេ នោះអាចនឹងជួបនូវវិបត្តិមួយចំនួនដោយសារ ៖

- គម្លាតរវាងអ្នកមាន និងអ្នកក្រកាន់តែធំ ដែលនាំឱ្យទំនាស់សង្គម និងបទឧក្រិដ្ឋផ្សេងៗកើតឡើង
- ហេតុផលនយោបាយ ដែលពេលខ្លះក្រុមណាមួយ ឬប្រជាពលរដ្ឋមួយភាគត្រូវបានបដិសេធ និងមិនរាប់បញ្ចូលក្នុងកិច្ចការនយោបាយ និងការអភិវឌ្ឍ
- មានការរើសអើង និងការរំលោភបំពានចំពោះប្រជាពលរដ្ឋដែលមានប្រវត្តិ វប្បធម៌ សាសនា ឬនិន្នាការផ្សេងគ្នា។
- ផ្សេងៗទៀត...។